ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០៦...១០៣...ប្រ.ក

លិខិតចូល
ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ2006

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- តាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦

## ស ំ រេ ច

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការគ្រប់គ្រង ដើម្បីដំណើរការប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (CIS) ដែលរួមមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១- | លោក ផាន់ ហូរ | អគ្គនាយករងធនាគារជាតិនៃកម្ពុជា | ប្រធាន |
| ២- | លោក រ័ត្ន សារុំធ | អគ្គនាយករងធនាគារជាតិនៃកម្ពុជា | អនុប្រធាន |

| | | |
|---|---|---|
| ៣-លោក មូ សាន់ | អគ្គនាយករងធនាគារវឌ្ឍនៈ | សមាជិក |
| ៤-កញ្ញា ជិន ម៉ៅ | នាយក នាយកដ្ឋានឥណទាន សាជីវកម្មធនាគារសិង្ហបុរី | សមាជិក |
| ៥-លោក វ៉ាន់ ថូ | នាយករងឥណទានធនាគារអេស៊ីលីដា ភីអិលស៊ី | សមាជិក |
| ៦-លោកឆយ វ៉ៃ ខុង | ប្រធានឥណទានធនាគារមេយប៊ែង សាខាភ្នំពេញ | សមាជិក |
| ៧-លោក ឡេង សេងឡុន | ជំនួយការផ្នែកគ្រប់គ្រងហានិភ័យធនាគារកាណាឌីយ៉ា ក.អ | សមាជិក |
| ៨-អ្នកស្រី ហេង គីរិយា | ប្រធានផ្នែកការិយាល័យព័ត៌មានុសាស្ត្រ | សមាជិក |

**ប្រការ ២.-**

គណៈកម្មាធិការគ្រប់គ្រងនៃប្រការ១ ខាងលើមានមុខងារ និងភារកិច្ចដូចខាងក្រោម ÷

- រៀបចំផែនការ និងចេញសេចក្តីសម្រេចដោយការពិគ្រោះយោបល់គ្នាលើបញ្ហាមួយចំនួនដូចតទៅ ÷
  - បញ្ហាទាក់ទងនឹងប្រភេទនៃព័ត៌មានឥណទានសំខាន់ៗ ដែលត្រូវបានប្រមូលដោយទីភ្នាក់ងារ និងរយៈពេលរក្សាទុក និងទំហំឥណទានដែលបានកំណត់ដូចដែលមានចែងក្នុងបញ្ញត្តិនៃប្រកាស និងក្រមប្រតិបត្តិដែលបានចូលជាធរមាន (មុននឹងអនុវត្តផែនការត្រូវទាមទារឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាមុនសិន)
  - បញ្ហាទាក់ទងនឹងការទទួល ការបែងចែក និងការទូទាត់ចំណាយប្រតិបត្តិការ ដែលកើតមានក្នុងដំណើរការនៃការធ្វើមជ្ឈការ ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មានឥណទានដោយទីភ្នាក់ងារ និងការវិនិយោគទៅលើគម្រោងថ្មី (មុននឹងអនុវត្តផែនការត្រូវទាមទារឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាមុនសិន)
  - បញ្ហាទាក់ទងនឹងការស៊ើបអង្កេតនូវលក្ខខណ្ឌជាក់ស្តែងដែលស្របតាមមុខងារ ភារកិច្ចរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុជាសមាជិក ដើម្បីផ្តល់ព័ត៌មានឥណទាន និងដាក់ទណ្ឌកម្ម (មុននឹងអនុវត្តផែនការ ត្រូវទាមទារឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាមុនសិន)
  - បញ្ហាទាក់ទងនឹងវិធានការទប់ស្កាត់ក្នុងករណីប្រើប្រាស់ខុស និងលេចចេញព័ត៌មានឥណទានសម្រាប់ប្រើប្រាស់ក្នុងគោលបំណងផ្សេង ក្រៅពីកិច្ចការដែលបានអនុញ្ញាតដោយប្រកាស
  - ចំណុចជាក់លាក់ចាំបាច់សម្រាប់ការធ្វើមជ្ឈការ ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មានឥណទាន និងការត្រួតពិនិត្យរបស់ក្រុមប្រតិបត្តិនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

- ប្រធានគណៈកម្មាធិការគ្រប់គ្រងជួសមុខឱ្យប្រធានក្រុមប្រឹក្សាភិបាល នៅពេលប្រធានក្រុមប្រឹក្សាភិបាលអវត្តមាន មានភារកិច្ចរៀបចំ ដឹកនាំការងារប្រចាំថ្ងៃជាទៀងទាត់។
- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវតែងតាំងលេខាប្រតិបត្តិ១រូប ក្នុងចំណោមសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីសម្រួលសកម្មភាពការងារទាំងឡាយរបស់គណៈកម្មាធិការគ្រប់គ្រង និងប្រាស្រ័យទាក់ទងរវាងគណៈកម្មាធិការគ្រប់គ្រង និងក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។ លេខាប្រតិបត្តិ ត្រូវធ្វើកំណត់ហេតុប្រជុំជូនសមាជិកគណៈកម្មាធិការគ្រប់គ្រង ព្រមទាំងរាយការណ៍ជូនតំណាងរបស់ធនាគារសមាជិក និងគ្រឹះស្ថានហិរញ្ញវត្ថុដែលចូលរួមផ្តល់ព័ត៌មានឥណទាន នៅពេលណាដែលពាក់ព័ន្ធ និងរក្សាទុកនូវឯកសារច្បាប់ដើម និងឯកសារពាក់ព័ន្ធនានា។
- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវតែងតាំងអ្នកដឹកនាំក្រុមប្រតិបត្តិ១រូប ប្រចាំក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។
- ប្រធានគណៈកម្មាធិការគ្រប់គ្រងដោយមានជំនួយពីអ្នកដឹកនាំក្រុមប្រតិបត្តិ ត្រូវរៀបចំនូវផែនការថវិកាប្រចាំឆ្នាំ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុម័តយល់ព្រម។
- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយមានជំនួយពីប្រធានក្រុមប្រតិបត្តិ និងដាក់ជូនរបាយការណ៍នេះទៅក្រុមប្រឹក្សាភិបាលដើម្បីអនុម័តយល់ព្រម។
- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំរបាយការណ៍ដែលបានអនុវត្តប្រចាំខែ និងដាក់ជូនរបាយការណ៍នេះទៅប្រធានក្រុមប្រឹក្សាភិបាល។
- ប្រធានគណៈកម្មាធិការគ្រប់គ្រង ត្រូវរៀបចំបង្កើតក្រុមការងារពិសេសមួយដើម្បីអនុវត្តការពិគ្រោះយោបល់បុន្មានចំណុចខាងលើឱ្យមានប្រសិទ្ធភាព។

**ប្រការ ៣.-**

ប្រធានគណៈកម្មាធិការគ្រប់គ្រងមានសិទ្ធិអញ្ជើញសមាសភាពគណៈកម្មាធិការគ្រប់គ្រង និងមន្ត្រីពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ និងធ្វើការងារតាមការចាំបាច់ ។ សមាជិកគណៈកម្មាធិការគ្រប់គ្រង ត្រូវទទួលខុសត្រូវគ្រប់កិច្ចការដែលប្រធានប្រគល់ឱ្យ ។

**ប្រការ ៤.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា និងសាមីជននៃប្រការ១ ខាងលើ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០០៦

ទេសាភិបាល

ជា_ចាន់តូ

**កន្លែងទទួល :**

- ដូចប្រការ ១ និងប្រការ ៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន :**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"